ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*****

លេខ.០២១/៩៩

# ដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួរលើកទី២

យើងឧត្តមសេនីយ៍ទោ សាវ ស៊ុខ ព្រះរាជអាជ្ញា-យោធា

- បានឃើញច្បាប់ស្តីពីការចាត់តាំងសកម្មភាពសាលាជំរះក្តីនៃកម្ពុជា ដែលប្រកាសឱ្យប្រើប្រាស់តាមក្រឹត្យលេខ ០៦ក្រ. ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣

- បានឃើញច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសអោយប្រើ តាមក្រិត្យលេខ ២១ក្រ. ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៣

- បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៣៩៧ ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ១៩៩៩

- បានឃើញដីកាបញ្ជូនរឿងទៅពិនិត្យ លេខ ១៥០ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ របស់ចៅក្រមស៊ើបអង្កេតនៃតុលាការយោធា ។

ក្រោយពីបានពិនិត្យសំណុំលិខិតខាងលើចប់សព្វគ្រប់ យល់ឃើញថា : ផ្អែកតាមលទ្ធផលស៊ើបអង្កេតរបស់ចៅក្រមស៊ើបអង្កេត និងចំលើយរបស់ឈ្មោះ អ៊ុំ ជឿន ហៅតា ម៉ុក ដែលបញ្ជាក់ថាឈ្មោះ ឌុចដែលជាប្រធានសន្តិសុខទុកទួលស្លែង ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលមានការពាក់ព័ន្ធក្នុងបទឧក្រិដ្ឋកម្មប្រឆាំងសន្តិសុខក្នុងប្រទេស ទិសដៅបំរើនយោបាយអោយក្រុមកម្ពុជាប្រជាធិបតេយ្យ ។

សំរេចចោទប្រកាន់ឈ្មោះ ឌុច ដែលពាក់ព័ន្ធជាមួយឈ្មោះ អ៊ុំ ជឿន ហៅតា ម៉ុក ពីបទប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងសន្តិសុខក្នុងប្រទេស ទិសដៅបំរើនយោបាយអោយក្រុមកម្ពុជាប្រជាធិបតេយ្យ ប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជា កាលពីកំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៩៩ ។

បទល្មើសដែលមានចែងអោយផ្តន្ទាទោសតាមមាត្រាទី២+៣+៤ នៃច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យ អោយនៅក្រៅច្បាប់ និងមាត្រា ៧ ចំណុច ក នៃក្រឹត្យ.ច្បាប់លេខ ០២ ។

បញ្ជូនសំណុំរឿង និង វត្ថុតាង ព្រមទាំងជនដែលពាក់ព័ន្ធទៅចៅក្រមស៊ើបអង្កេត ដើម្បីស៊ើបសួរ និងចេញដីកាឃុំខ្លួនឈ្មោះ ឌុច តាមផ្លូវច្បាប់ ។

ភ្នំពេញ ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៩

ស្ថាប័នអយ្យការយោធា

ព្រះរាជអាជ្ញារង

ឧត្តមសេនីយ៍ទោ សាវ-ស៊ុខ